# កម្ពុជា

# របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#២២

៣០ វិច្ឆិកា ឆ្នាំ២០២០

របាយការណ៍គិតត្រឹមថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ម៉ោង១០:០០នាទីព្រឹក

## ស្ថានការណ៍សង្ខេប

សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន

- ករណីថ្មីកើតឡើងជាក្រុមនៅគេហដ្ឋានមួយ (មានចំនួន ៦ ករណីដែលមាន ស្រី ២នាក់ និង ប្រុស ៤នាក់) កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០២០ ។ ករណីដំបូងបានធ្វើតេស្តវិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០២០ ក្រោយមានរោគសញ្ញាគ្រុនផ្តាសាយកាលពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២០។ កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០២០ អ្នកដែលបានប៉ះពាល់ ៨នាក់ទៀតបានធ្វើតេស្តវិជ្ជមាន ហើយការធ្វើអង្កេតតាមដានជំងឺ និងការសម្ភាសករណីទាំងអស់ក៏បាននិងកំពុងចាប់ផ្តើមដំណើរការផងដែរ។ ពាក់ព័ន្ធករណីជាក្រុមនេះ មានវត្ថុសំណាកវិភាគសរុប ២ ២៤៨ករណី ត្រូវបានធ្វើតេស្តនៅថ្ងៃនេះ ដែលក្នុងនោះមាន ១៤ករណី វិជ្ជមានជំងឺកូវីដ១៩ (ស្មើរនិង ០,៦២%) នៃករណីសរុប។
- កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោង ១០ព្រឹក (ម៉ោងសកល) មានចំនួនសរុប ៣២៣ ករណី ដែលបានបញ្ជាក់ជាជំងឺគូវីដ១៩ ដែលបានរាយការណ៍មក អង្គការសុខភាពពិភពលោក ក្នុងចំណោមនោះមានចំនួន ៣០១ ករណី បានជាសះស្បើយ។ ចំនួន ២៦៧ ករណី ដែលទទួលបានពី ១៦សញ្ជាតិ ផ្សេងៗគ្នា បន្ថែមទៅលើជនជាតិខ្មែរ ដែលទទួលបានការឆ្លងនៅក្នុងស្រុក។ អ្នកជំងឺកូវីដ-១៩ ចំនួន ១៤នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។
- ក្នុងការឆ្លើយតបទៅនិងព្រឹត្តការណ៍កើតឡើងជាក្រុម សម្តេចនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានណែនាំអ្នកប៉ះពាលើជាក្រុមទាំងអស់ត្រូវធ្វើចត្តាឡីស័ក្កតាមផ្ទះរបស់ខ្លួន រឺនៅមណ្ឌលចត្តាឡីស័ក្កតាមបណ្តាខេត្តរៀងៗខ្លួន។ រាជរដ្ឋាភិបាល បានបិទផ្សារអេអន១ រយះពេល ២ ទៅ៣ថ្ងៃ ដើម្បីធ្វើការស្រាវជ្រាវ និង តាមដានអ្នកដែលបានប៉ះពាល់។ អាជ្ញាធរក្រោមជាតិ និង មន្ទីរសុខាភិបាលខេត្តទាំងអស់ និងបន្តធ្វើការស្រាវជ្រាវ និង តាមដានអ្នកដែលបានប៉ះពាល់ទាំងអស់។ ក្រសួងសុខាភិបាលបានណែនាំដល់អ្នកដែលបានប៉ះពាល់ទាំងអស់មកបង្ហាញខ្លួន ដើម្បីយកសំណាកវិភាគ និងធ្វើតេស្តដែលមាននៅ ក្រសួងមហាផ្ទៃ ផ្សារអេអន១ និង ពន្ធនាគារព្រៃស និងនៅខេត្តសៀមរាបនៅសាលាគរុកោសល្យខេត្តសៀមរាប នៅថ្ងៃ ២៩ វិច្ឆិកា។
- កាលថ្ងៃទី ២៩ វិច្ឆិកា ក្រសួងអប់រំបានប្រកាសបិទសាលាឯកជនទាំងអស់ចំនួន ពីសប្តាហ៍
- អង្គការសុខភាពពិភពលោក និង មជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជំងឺឆ្លងនៃសហរដ្ឋអាមេរិក (USCDC) បានរាយការណ៍ទៅក្រសួងសុខាភិបាលដើម្បីពិនិត្យករណីទាំងអស់ ហើយធ្វើការស្រាវជ្រាវករណីកើតឡើងជាក្រុមដោយមានគោលបំណងសំខាន់ៗពីររួមមាន
    - ការប្រមើមើលទៅលើអ្នកប៉ះពាល់ដើម្បី កំណត់សញ្ញាទៅលើអ្នកដែលបានប៉ះពាល់ បញ្ឈប់ហានិភ័យ និង ការធ្វើចត្តាឡីស័ក្ក
    - ការស្រាវជ្រាវករណីឡើងវិញដើម្បី កំណត់ប្រភពសញ្ញានៃការឆ្លង
- ក្រសួងអប់រំ យុវន និង កីឡា និងធ្វើយុទ្ធនាការផ្សព្វផ្សាយសៀវភៅណែនាំដែលមានចំណងជើងថា " ការបើកសាលារៀនឡើងវិញក្នុងបរិបទជំងឺកូវីដ១៩ " នៅថ្ងៃទី ០៧ ធ្នូខាងមុខនេះ។
- នៅក្នុងខែវិច្ឆិកា ចំនួនបុគ្គលិកសុខាភិបាលសរុប ២៩០ នាក់ និងប្រធានភូមិចំនួន ២០៨ នាក់ រួមទាំងក្រុមអ្នកស្ម័គ្រចិត្តជាច្រើនទទួលបានចំណេះដឹង និង ជំនាញអំពីការគាំទ្រនិងការថែរទាំសុខភាពផ្លូវចិត្ត និងក្នុងបរិបទជំងឺកូវីដ១៩។ ក្រុមជំនាញដែលបានទទួលការណ្តុះបណ្តាលទាំងនេះ និងបន្តជួយ នឹងផ្តល់ការគាំទ្រនិងការថែរទាំសុខភាពផ្លូវចិត្តដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ រួមទាំងពលរដ្ឋដែលបានធ្វើមាតុភូមិនិវត្តនៅក្នុងសហគមន៍របស់ពួកគេ ដែលជាផ្នែកមួយនៃការផ្តល់សេវាថែរទាំសុខភាពជាប្រចាំផងដែរ។
- ផែនការមេថ្នាក់ជាតិស្តីអំពីជំងឺកូវីដ-១៩ បានដាក់បញ្ចូលនូវការបង្កើតគណៈកម្មាធិការពហុវិស័យថ្នាក់រាជធានី-ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត។ ផែនការនានាត្រូវបាននិងកំពុងបង្កើតឡើងដើម្បីពង្រឹងសមត្ថភាពថ្នាក់ខេត្ត និង ស្រុកជុំវិញសកម្មភាពអាទិភាពសំខាន់ៗមួយចំនួន។
- ក្រសួងសុខាភិបាល កំពុងដឹកនាំអង្គការ ស្ថាប័ណ្ណពាក់ព័ន្ធទាំងអស់ដើម្បីពិនិត្យវាយតំលៃនៃគោលការណ៍សុខភាពអន្តរជាតិ និងផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០១៦ - ២០២០។ នៅក្នុងឆ្នាំនេះនិងមានបញ្ចូលបន្ថែមនូវកត្តាមួយចំនួនស្តីពីការចំណាយទៅលើជំងឺកូវីដទូទាំងប្រទេស។

## ព្រឹត្តិការណ៍ដែលនឹងកើតមាន និងវិធានការអាទិភាព



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- យុទ្ធនាការអប់រំអំពីហានិភ័យនៃជំងឺកូវីដ១៩ បានផ្តោតទៅលើក្រុមពលរដ្ឋវ័យក្មេង ដែលនិងធ្វើឡើងនៅដើមខែកុម្ភៈខាងមុខនេះ។ គោលបំណងនៃយុទ្ធនាការ គឺធ្វើឡើងដើម្បីអប់រំផ្សព្វផ្សាយថា ហានិភ័យនៃជំងឺកូវីដ១៩ នៅតែបន្តកើតមាននៅក្នុងប្រទេសកម្ពុជា ហានិភ័យនិងនៅតែកើតមានរហូតដល់ការឆ្លងរាលដាលត្រូវបានបញ្ចប់ ហើយត្រូវធ្វើការជំរុញ និងលើកទឹកចិត្តដល់ក្រុមចំណុចអោយមានការបំផុសបំផុលជាវិជ្ជមានដល់អ្នក ផ្សេងៗទៀត ( ជាដៃគូរ ជាគ្រួសារ និង ជាសហគមន៍)។
- ក្រសួងអប់រំ យុវន និង កីឡានិងធ្វើយុទ្ធនាការផ្សព្វផ្សាយសៀវភៅណែនាំដែលមានចំណងជើងថា "ការបើកសាលារៀនឡើងវិញក្នុងបរិបទជំងឺកូវីដ១៩ " នៅថ្ងៃទី ០៧ ធ្នូខាងមុខនេះ។
- ក្រុមឆ្លើយតបបន្ទាន់នៅទូរទាំងប្រទេសត្រូវបានការបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងតាមដានអ្នកជំងឺ និងអ្នកដែលបានប៉ះពាល់អ្នកជំងឺ។ ការបណ្តុះបណ្តាលនេះ បច្ចុប្បន្នត្រូវបានបញ្ចប់ ដោយបានធ្វើសិក្ខាសិលាសរុបទាំងអស់ជាង ១០០ លើក។
- ក្រសួងសុខាភិបាលបានធ្វើការវាយតំលៃថ្នាក់ជាតិនូវការឆ្លងរាលដាលជំងឺកូវីដ១៩ ជាប្រចាំសប្តាហ៍ ដោយមានការប្រើពហុប្រភពព័ត៌មានពីការអង្កេតតាមដានផ្សេងៗជាច្រើន។ ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក កំពុងធ្វើការគាំទ្រដល់ខេត្តដើម្បីធ្វើការវាយតំលៃនូវការវិវត្តន៍នូវដំណាក់កាលក្នុងខេត្តរបស់ខ្លួន។
- ក្រសួងសុខាភិបាល កំពុងដំណើរការផែនការពង្រឹងសមត្ថភាព និងផ្ទេររំលែកការងារធ្វើតេស្តពិសោធន៍រកករណីកូវីដ-១៩ ទៅដល់មន្ទីរពិសោធន៍ក្នុងខេត្តចំនួនបី គឺខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ គម្រោងស្នើសុំមូលនិធិសម្រាប់ការពង្រីកសមត្ថភាពធ្វើរោគវិនិច្ឆ័យម៉ូលេគុលត្រូវបានដាក់ទៅកាន់អង្គការមូលនិធិសកលរួចហើយនៅសប្តាហ៍នេះ។ ការធ្វើតេសនៅមន្ទីពិសោធន៍ថ្មីក្នុងខេត្តសៀមរាប កំពុងដំណើរការបន្តនិងបានបង្កើនសមត្ថភាពធ្វើតេស្តនៅមន្ទីរពិសោធន៍ថ្នាក់ខេត្តពីលើមន្ទីរពិសោធន៍ចំនួនបីដែលមានស្រាប់។ សកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាលត្រូវបានអនុញ្ញាតឲ្យចាប់ផ្តើមធ្វើតេស្តសម្រាប់រយៈពេលសាកល្បងចំនួនមួយខែ។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងបញ្ចប់កំណែលើកទី៣នៃគោលការណែនាំគ្លីនិក។ គោលការណ៍ណែនាំនេះ មានរួមបញ្ចូលមាតិកាស្តីពីការគ្រប់គ្រងករណីជំងឺធ្ងន់ធ្ងរ ឧបករណ៍ចម្រោះអុកស៊ីសែន និងនីតិវិធីសម្រាប់តាមដានវីរុសកូវីដ-១៩ (SARS-CoV-2) លក្ខណៈវិច្ឆ័យសម្រាប់ការអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ ការប្រើប្រាស់ឱសថ និងការគ្រប់គ្រងក្រោយពេលចេញពីមន្ទីរពេទ្យ។ សេចក្តីសង្ខេបបច្ចេកទេសមួយស្តីពីជំងឺកូវីដ-១៩ សុខភាពបន្តពូជ មាតា និងទារក ដែលមជ្ឈមណ្ឌលសុខភាពមាតា និងទារកដឹកនាំរៀបចំ នឹងត្រូវធ្វើរួចរាល់ ដើម្បីបំពេញបន្ថែមឲ្យគោលការណ៍ណែនាំគ្លីនិក។
- កម្មវិធីជាត់ផ្តល់ថ្នាំបង្ការ បានធ្វើពង្រៀងផែនការថ្នាក់ជាតិស្តីពីការដាក់អោយប្រើប្រាស់ និង ការផ្តល់វ៉ាក់សាំងកូវីដ១៩ ដោយផ្តោតទៅលើសកម្មភាពមួយចំនួនដូចខាងក្រោម
  - ការវាយតំលៃសមត្ថភាពប្រព័ន្ធត្រជាក់
  - យុទ្ធសាស្រ្តការផ្តលើវ៉ាក់សាំង
  - ការគ្រប់គ្រងរចនាសម្ព័ន្ធ
- រាជរដ្ឋាភិបាលកំពុងបន្តវាយតម្លៃពីការកែតម្រូវអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្រ្ត (Non-Pharmaceutical Intervention) ដោយប្រើវិធីសាស្រ្តជាជំហានៗ និងពិនិត្យទៅលើប្រសិទ្ធភាព ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម ក៏ដូចជាពិនិត្យទៅលើថាតើសធារណៈជនទទួលយកបាននូវវិធានការណ៍នីមួយៗដែលបានដាក់ចេញដែរឬទេ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការតាមដានជំងឺដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវ។
- ក្រសួងសុខាភិបាល បានបង្កើតគណៈកម្មាធិការមួយដើម្បើដឹកនាំការរៀបចំ និងដំណើរការសិក្ខាសាលាថ្នាក់តំបន់ចំនួន៦ ដើម្បីជួយគាំទ្រការធ្វើផែនការថ្នាក់ខេត្ត-រាជធានី និងការត្រៀមបង្ការថ្នាក់មូលដ្ឋាន ប្រយោជន៍ដើម្បីធានាឲ្យមានការឆ្លើយតបទាន់ពេលវេលា និងមានប្រសិទ្ធភាពចំពោះការផ្ទុះឡើងនូវជំងឺកូវីដ-១៩នៅក្នុងសហគមន៍នៅពេលខាងមុខណាមួយ ហើយនិងដើម្បីកាត់បន្ថយការរាំងស្ទះដល់ការផ្តល់សេវាសុខភាពសំខាន់ៗនៅក្នុងសហគមន៍។ ការរៀបចំសិក្ខាសាលាទាំងនេះ គឺដើម្បីបង្កើតឬកែសម្រួលឲ្យកាន់តែប្រសើរឡើងនូវផែនការសកម្មភាពត្រៀមបង្ការថ្នាក់ខេត្ត-រាជធានី ឲ្យស្របទៅតាមផែនការមេថ្នាក់ជាតិស្តីអំពីជំងឺកូវីដ-១៩ និងដើម្បីកំណត់អាទិភាពសំខាន់ៗសម្រាប់ពង្រឹងការត្រៀមបង្ការនៅថ្នាក់មូលដ្ឋាន។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# ការវាយតម្លៃនៃអត្រាឆ្លងជំងឺថ្នាក់ជាតិ

**១. នាំចូល-** គិតត្រឹមថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២០នេះ ករណីវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ២៦៧ ករណី (៨៣%) នៃចំនួនករណីសរុប ៣២៣ ករណី ដែលបាននាំចូលពីបរទេស ហើយចំនួនសេសសល់ជាករណីឆ្លងក្នុងប្រទេស ហើយការតាមដានស្រាវជ្រាវអ្នកប៉ះពាល់ក៏បាននិងកំពុងបន្តសំរាប់ករណីពាក់ព័ន្ធឆ្លងក្នុងផ្ទះជាក្រុម។ បច្ចុប្បន្ន មិនមានរបាយការណ៍ណាមួយដែលបានរាយការណ៍អំពីការកើតមានជំងឺផ្លូវដង្ហើមជាក្រុម ដែលមិនបានធ្វើរោគវិនិច្ឆ័យឃើញ តាមរយៈការរាយការណ៍តាមបណ្តាញទូរស័ព្ទបន្ទាន់នោះទេ។ របាយការណ៍អំពីករណីជំងឺស្រដៀងផ្តាសាយ និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរនៅក្នុងខែវិច្ឆិកានេះមានកម្រិតទាបជាងកម្រិតដែលយើងបានរំពឹងទុក ដែលកម្រិតនេះមិនខុសពីកម្រិតនៅតំបន់ផ្សេងៗទៀតនៅទូទាំងពិភពលោកនោះទេ។ មនុស្សចំនួនករណី ១៤៩ ៩៦០នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិជ្ជាធ្វើតេស្តបែប PCR (Polymerase chain reaction, PCR) ជាមួយនឹងអត្រាវិជ្ជមានចំនួន ០,២១%។ ការធ្វើតេស្តសរុបមានចំនួន ១៩៨ ៨៩២ ករណី គិតត្រឹមថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២០ ដែលក្នុងនោះមានតេស្តទៅលើសំណាកបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (influenza-like illness, ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (severe acute respiratory infections, SARI) ការតេស្តសំណាកចំនួន ៣ ៨២១ ទទួលបានលទ្ធផលអវិជ្ជមានវីរុសកូវីដ-១៩ (SARS-CoV2)។ ជាផ្នែកមួយនៃការឆ្លើយតបទៅនិងព្រឹត្តការណ៍ ២៣ វិច្ឆិកា ចំនួនសំណាកវិភាគសរុបទាំងអស់ ២ ២៤៨ករណី ត្រូវបានធ្វើតេស្ត ។

## បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩

| ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | ករណីសង្គ្រោះបន្ទាន់ |
|---|---|---|---|
| 9,876<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | 17<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(325% - ៧ថ្ងៃ) | 0<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(០ភាគរយ-៧ថ្ងៃ) | 0<br>ករណីសង្គ្រោះបន្ទាន់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(០ភាគរយ-៧ថ្ងៃ) |
| 198,892<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 323<br>ករណីសរុប | 0<br>ករណីស្លាប់សរុប | 0<br>ករណីសង្គ្រោះបន្ទាន់សរុប |

| | | | |
|---|---|---|---|
| 100%<br>ចំនួនករណីនាំចូលពីបរទេសក្នុងពេល២៨ថ្ងៃចុងក្រោយ(23) | 0%<br>ចំនួនករណីក្នុងរយៈពេល២៨ចុងក្រោយដែលគ្មានព័ត៌មានពាក់ព័ន្ធ (0) | 0<br>ចង្កោមសកម្ម | 0<br>ចង្កោមសកម្មដោយបានឆ្លងលើសបីតំណ |

## ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩

| | | | |
|---|---|---|---|
| 0<br>ចំនួនករណីបុគ្គលិកថែទាំសុខភាពដែលត្រូវបានរាយការណ៍កាលពីសប្តាហ៍កន្លងមក | 27<br>ចំនួនមន្ទីរពេទ្យដែលទទួលអ្នកជំងឺកូវីដ-១៩ឲ្យសម្រាកព្យាបាល | 13,667<br>ចំនួនគ្រែមន្ទីរពេទ្យរដ្ឋសរុប | 17<br>ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩ |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អេពីដេមីសាស្ត្រ

ក្រាហ្វិកទី១. ចំនួនករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍បែងចែកតាមស្ថានភាពនៃការឆ្លង និងកាលបរិច្ឆេទនៃលទ្ធផលតេស្តវិជ្ជមាន




**តារាងទី១. តារាងនៃករណីឈឺសរុប និងថ្មី (ក្នុងរយៈពេល៧ថ្ងៃចុងក្រោយ) និងករណីស្លាប់ បែងចែកតាមអាយុ និងភេទ**

| ក្រុមនៃអាយុ | ស្រី | | ប្រុស | | សរុប |
|---|---|---|---|---|---|
| | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ |
| 0-9 | 1(0) | 0(0) | 3(1) | 0(0) | 4(1) |
| 10-19 | 1(0) | 0(0) | 4(1) | 0(0) | 5(1) |
| 20-29 | 12(1) | 0(0) | 108(0) | 0(0) | 120(1) |
| 30-39 | 19(4) | 0(0) | 61(4) | 0(0) | 80(8) |
| 40-49 | 8(1) | 0(0) | 21(0) | 0(0) | 29(1) |
| 50-59 | 11(1) | 0(0) | 19(1) | 0(0) | 30(2) |
| 60-69 | 16(1) | 0(0) | 29(0) | 0(0) | 45(1) |
| 70-79 | 2(0) | 0(0) | 5(0) | 0(0) | 7(0) |
| 80-89 | 0(0) | 0(0) | 0(0) | 0(0) | 0(0) |
| 90+ | 0(0) | 0(0) | 0(0) | 0(0) | 0(0) |
| មិនដឹង | 1(1) | 0(0) | 2(1) | 0(0) | 3(2) |
| សរុប | 71(9) | 0(0) | 252(8) | 0(0) | 323(17) |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ក្រាហ្វិកទី២. ចំនួនសមាមាត្រនៃករណីឃើបញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមក្រុមអាយុ និងសញ្ជាតិ (ចំនួន ៣២៣ នាក់)




ក្រាហ្វិកទី៣. ចំនួនករណីជំងឺស្រដៀងផ្តាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្តាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្តាហ៍ ឆ្នាំ២០២០ និងពីឆ្នាំ២០១៧ ដល់ឆ្នាំ ២០១៩






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី៤. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្តាហ៍ ឆ្នាំ២០២០ និងពីឆ្នាំ២០១៧ ដល់២០១៩**




# អភិក្រមយុទ្ធសាស្រ្ត

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- គណៈកម្មាធិការអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាមួយនឹងរដ្ឋលេខាធិការ
- គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ ដែលដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺកូវីដ១៩ថ្នាក់រាជនានី-ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះបាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រិត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩ វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។

## គន្លឹះអាទិភាពសំខាន់ៗ

- នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសុខាភិបាល កំពុងរៀបចំបង្កើតយុទ្ធសាស្រ្តថែទាំសុខភាពបឋមសម្រាប់ជំងឺកូវីដ-១៩។ ឯកសារនេះ នឹងដាក់បញ្ចូលតួនាទី និងភារកិច្ចនានារបស់មណ្ឌលសុខភាពនៅក្នុងសេណារីយ៉ូមួយដែលអាចកើតមាននូវការឆ្លងជំងឺកូវីដ-១៩ទៅក្នុងសហគមន៍ ក៏ដូចជាគោលការណ៍គ្រប់គ្រងគ្លីនិក និងការបង្ការ និងត្រួតពិនិត្យការឆ្លងរោគ។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការស្ទង់មតិមួយអំពីវគ្គបណ្តុះបណ្តាលកន្លងមកពីការគ្រប់គ្រងគ្លីនិក ការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ ដើម្បីរៀបចំបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិមួយសំរាប់បញ្ហាជំងឺកូវីដ-១៩។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃទាក់ទងនឹងការត្រៀមខ្លួនរបស់ប្រព័ន្ធសុខាភិបាល នៅតាមមូលដ្ឋានថែទាំសុខភាព ទាក់ទងនឹងសមត្ថភាពសង្គ្រោះបន្ទាន់ (ICU) អុកស៊ីសែន បុគ្គលិកសុខាភិបាលជាដើម។
- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- កំពុងដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រពង្រីកមន្ទីរពិសោធន៍ ដើម្បីធានាឲ្យមានការធ្វើតេស្តគ្រប់គ្រាន់ជាប្រចាំសម្រាប់ជំងឺកូវីដ-១៩។
- ការពង្រឹងការធ្វើចត្តាឡីស័កនៅតាមមូលដ្ឋានថែទាំសុខភាព ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ ដោយបង្កើតជាឧបករណ៍ជំនួយការងារសាមញ្ញៗសម្រាប់បុគ្គលិកនៅមូលដ្ឋានថែទាំសុខភាព។
- ផែនការយុទ្ធសាស្ត្រឆ្លើយតបបន្ទាន់ និងផែនការសកម្មភាពដើម្បីស្វែងរក និង ឆ្លើយតបក្នុងព្រឹត្តិការណ៍ដែលមានការឆ្លងរាលដាលជំងឺកូវីដ១៩នៅក្នុងសហគមន៍ ជាពិសេសនៅក្នុងបរិបទដូចជាការឆ្លងរាលដាលនៅតាមសាលារៀន វត្តអារាម និង ពន្ធនាគារជាដើមត្រូវរៀបចំរួចជាស្រេច។
- ពង្រឹងការប្រើប្រាស់ការតាមដានជំងឺដោយប្រើពហុប្រភពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់វាយតម្លៃហានិភ័យ និងការធ្វើសេចក្តីសម្រេចចិត្ត។
- ការពង្រីកសមត្ថភាពធ្វើតេស្តរកកូវីដ-១៩ នៅមន្ទីរពិសោធន៍។
- ពង្រឹងសមត្ថភាពត្រៀមបង្ការនៅថ្នាក់មូលដ្ឋាន ក្នុងករណីមានការផ្ទុះរាលដាលជំងឺនៅសហគមន៍នាពេលអនាគត និងដើម្បីកាត់បន្ថយការរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាពសំខាន់ៗ។

## អភិក្រមយុទ្ធសាស្ត្រសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- *យុទ្ធសាស្ត្រសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្ត្រធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី១៣ ពេលបញ្ចប់ចត្តាឡីស័ក១៤ ថ្ងៃ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ យុទ្ធសាស្ត្រតាមដានជំងឺ កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់ នៅតាមតំបន់ដែលប្រឈមខ្ពស់ ឬតំបន់ដែលមានករណីវីរុសកូវីដ-១៩ ច្រើន (Hot-spot surveillance strategies) ក៏ដូចការធ្វើតេស្តទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations)។

- *ការទំនាក់ទំនង និងផ្សព្វផ្សាយពីហានិភ័យ និងការចូលរួមរបស់សហគមន៍*
    - បណ្តុះបណ្តាស្តីពីការការពារ និងការយុទ្ធប្រឆាំងជំងឺកូវីដ១៩ នៅពេលសាលារៀនបើកដំណើរឡើងវិញ
- បន្តផ្តល់ការបណ្តុះបណ្តាលដល់នាយក នាយរងសាលា លោកគ្រូ អ្នកគ្រូ ដែលទទួលខុសត្រូវផ្នែកសុខភាពតាមសាលារៀន រួមទាំងតំណាងការិយាល័យអប់រំខ័ណ្ឌទូទាំងរាជធានីភ្នំពេញស្តីអំពីការការពារ និងការយុទ្ធប្រឆាំងជំងឺកូវីដ១៩ អំឡុងពេលសាលារៀនបើកដំណើរឡើងវិញ កាលពីថ្ងៃទី ៥ - ៧ តុលា ២០២០ នៅក្រសួងអប់រំ។ ចំនួនសិក្ខាកាមសរុបទាំងអស់ ៩៨នាក់ដែលបានចូលរួមទទួលការបណ្តុះបណ្តាល។
- ការបណ្តុះបណ្តាលស្តីពីការគាំទ្រ និង ការថែទាំសុខភាពផ្លូវចិត្ត ដែលជាផ្នែកមួយនៃជំងឺកូវីដ១៩
    - បុគ្គលិកសុខភាពជំនាញសរុប ៧០នាក់ (បុគ្គលិកសុខភាព) មកពីមន្ទីរពេទ្យបង្អែកខេត្តរតនគីរីរួមមានដូចជា ស្រុកបាលុង អូជុំ និងបរកែវ ស្រុកអណ្តូងមាស អូយ៉ាដាវ និងស្រុកកូនមុម ស្រុកលំផាត់ តា វាង និងស្រុកវឿនសៃ ជាមួយគ្នានោះក៏មានប្រធានភូមិ ៥០នាក់ និងរួមមានក្រុមអ្នកស្ម័គ្រចិត្ត ៥០នាក់ មកពីស្រយកច្ឆគោល ខេត្តបាត់ដំបងផងដែរ ។
    - បុគ្គលិកសុខភាពជំនាញសរុប ៦៥នាក់ (បុគ្គលិកសុខភាព) មកពីមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែក បុរីអូស្វាយសែនជ័យ និង ស្រុកសៀមបូក ស្រុកសៀមប៉ាង និង ស្រុកសេសាន ក្រុងស្ទឹងត្រែង ស្រុកថាឡាបរិវ៉ាត់ នៃខេត្តស្ទឹងត្រែង។ បុគ្គលិកសុខភាពជំនាញដែលបានបណ្តុះបណ្តាលហើយ និងបន្តផ្តល់ការគាំទ្រ និង ការថែទាំសុខភាពផ្លូវចិត្តបានត្រឹមត្រូវដល់ពលរដ្ឋដែលងាយរងគ្រោះ រួមទាំងរួមទាំងពលរដ្ឋដែលបានធ្វើមាតុភូមិនិវត្តន៍នៅក្នុងសហគមន៍របស់ពួកគេ ដែលជាផ្នែកមួយនៃការផ្តល់សេវាថែទាំសុខភាពជាប្រចាំផងដែរ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*

# បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

## កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
  - ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្ដេចតេជោនាយករដ្ឋមន្ត្រី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្ត្រីសុខាភិបាល។
  - ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។
- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
  - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្ដាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
  - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**
  - សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្ដាញសង្គម និងតាមរយៈសេចក្ដីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
  - សម្ភារទំនាក់ទំនងសម្រាប់ទស្សនិកជន និងអ្នកស្ដាប់គោលដៅ ត្រូវបានបង្កើតឡើងសម្រាប់ក្រុមដែលមានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) និងកម្មកររោងចក្រ។
  - យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្ដប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។
- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។

# អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (Non-Pharmaceutical Interventions, NPIs)

អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រទ្រង់ទ្រាយធំ ដែលត្រូវបានប្រកាសនៅថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០ រួមមានការបិទគ្រឹះស្ថានសិក្សាទូទាំងប្រទេស ហើយជំនួសវិញដោយដំណើរការសិក្សាតាមអនឡាញ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

នៅថ្ងៃទី ២១ ខែកក្កដា ទីស្ដីការគណៈរដ្ឋមន្ត្រី បានចេញសេចក្ដីប្រកាសមួយ អនុញ្ញាតឲ្យសាលារៀនឯកជនស្តង់ដារសុវត្ថិភាពខ្ពស់ ចំនួន២០ នៅភ្នំពេញ សៀមរាប និងបាត់ដំបង បើកដំណើរការឡើងវិញចាប់ពីខែសីហា នៅក្នុងដំណាក់កាលទី១នៃផែនការបើកសាលារៀនឡើងវិញដែលមានបីដំណាក់កាល។ ដំណាក់កាលទី១ គឺសម្រាប់សាលាដែលមានស្តង់ដារខ្ពស់ ដំណាក់កាលទី២សម្រាប់សាលាដែលមានស្តង់ដារមធ្យម និងដំណាក់កាលទី៣សម្រាប់សាលាដែលមានស្តង់ដារកម្រិតអប្បបរមា។ កាលពីថ្ងៃទី២៥ ខែសីហា ក្រសួងអប់រំយុវជននិងកីឡា បានដាក់ចេញនូវគោលការណែនាំសម្រាប់ដំណាក់កាលទីពីរនៃផែនការបើកសាលារៀនឡើងវិញ។ ក្រោយពីបិទអស់រយៈពេល៦ខែមក ខេត្តចំនួន៤ដែលមានហានិភ័យឆ្លងជំងឺកូវីដ-១៩កម្រិតទាប (ក្រចេះ ស្ទឹងត្រែង រតនៈគិរី និង មណ្ឌលគិរី) ត្រូវបានអនុញ្ញាតឲ្យបើកឡើងវិញនូវសាលារៀនគ្រប់កម្រិតចាប់តាំងពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់វិទ្យាល័យ ខណៈដែលខេត្តដទៃទៀតអាចបើកដំណើរការឡើងវិញសម្រាប់ថ្នាក់ទី៩ និងទី១២។ វិធានការសុវត្ថិភាព រួមមានការតម្រូវឲ្យមានសិស្សចំនួនតែ២០នាក់យ៉ាងច្រើនក្នុងមួយថ្នាក់ ហើយសិស្សម្នាក់ៗត្រូវតែអង្គុយឃ្លាតពីគ្នាឲ្យបានយ៉ាងហោចណាស់ក៏២ម៉ែត្រ។

- កាលពីថ្ងៃទី២១ខែកញ្ញាឆ្នាំ ២០២០ ក្រសួងអប់រំយុវជននិងកីឡា បានអនុញ្ញាតឲ្យប្រធានមន្ទីរអប់នៅទូទាំងប្រទេសចុះហត្ថលេខាលើអនុសារណៈនៃការយោគយល់ និងចេញប័ណ្ណអនុញ្ញាតសម្រាប់សាលាដែលចេញដោយការិយាល័យច្រកចេញចូលតែមួយរបស់មន្ទីរអប់រំ។ សាលាទាំងអស់ដែលទទួលបានការអនុញ្ញាតពីការិយាល័យច្រកចេញចូលតែមួយ អាចបើកដំណើរការរបស់ខ្លួនឡើងវិញបាន។ កាលពី ថ្ងៃទី១៥ តុលាកន្លងទៅនេះ ក្រសួងអប់រំយុវជននិងកីឡា បានអនុញ្ញាតឲ្យសកលវិទ្យាល័យសាធារណៈទាំងអស់បើកដំណើរឡើងវិញ ដោយអនុវត្តនូវគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និង អង្គការសុខភាពិភពលោកអោយបានខ្ជាប់ខ្ជួនបំផុត។ កាលពីថ្ងៃទី ០២ វិច្ឆិកា ក្រសួងអប់រំ យុវជន និង កីឡាបានអនុញ្ញាត្តិអោយសាលារៀនទាំងអស់ទូរទាំងប្រទេសបើកឡើងវិញក្នុងកំណត់កាលទី៣។ ក្រសួងអប់រំ យុវជន និង កីឡាបានប្រកាសថា ការអនុវត្តន៏គោលការណ៍សុខភាព និង សុវត្ថិភាពនៅតាមសាលារៀននៅតែមានសារៈសំខាន់ខ្ពស់បំផុត។ នៅក្នុងដំណាក់កាលទីបី គ្រប់សាលារដ្ឋ និង សាលាឯកជនទាំងអស់បើកដំណើរការឡើងវិញជាធម្មតា។ កាលពីថ្ងៃទី០៨ វិច្ឆិកា ក្រសួងអប់រំ យុវជន និង កីឡា បានប្រកាសថា សិស្សនុសិស្សទាំងអស់ណាដែលបានចូលរួមក្នុងព្រឹត្តិការណ៍ពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវធ្វើចត្តាឡីស័ក្ក ហើយមិនត្រូវមកសាលារៀន រឺ សកលវិទ្យាល័យឡើយ។ សាលារៀនទាំងអស់នៅទីក្រុងភ្នំពេញ និង ខេត្តកណ្តាលត្រូវបិទបណ្តោះអាសន្នពីសប្តាហ៍។ សាលារៀនទាំងអស់នៅទីក្រុងភ្នំពេញ និង ខេត្តកណ្តាលត្រូវបានបើកដំណើរឡើងវិញនៅថ្ងៃទី ២៣ វិច្ឆិកានេះ។

ខារ៉ាអូខេ និងក្លឹបកំសាន្ត ត្រូវបានបិទដំណើរការនៅថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០២០។ នៅថ្ងៃទី៧ ខែកក្កដា សាលារាជធានីភ្នំពេញ បានប្រកាសថាខារ៉ាអូខេ និង ក្លឹបកំសាន្តនានា អាចបើកដំណើរការឡើងវិញបាន ទាល់តែកែច្នៃខារ៉ាអូខេ និងក្លឹបកំសាន្តទាំងនោះ អោយទៅជាភោជនីយដ្ឋានវិញ ហើយនិងទទួលបានការអនុញ្ញាតពីសាលារាជធានីទើបអាចបើកដំណើរការបាន។ ទីតាំងទាំងនោះ ត្រូវតែគោរពតាមវិធានការនានាដែលចេញដោយក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ដូចជារក្សាគម្លាតសុវិត្ថិភាព រក្សាទីតាំងអោយមានខ្យល់អាកាសចេញចូល និងវិធានការប្រុងប្រយ័ត្នផ្សេងៗទៀត។

- ដើម្បីកាត់បន្ថយការនាំចូលករណីកូវីដ-១៩ពីបរទេស ការមកដល់នៃអ្នកដំណើរនៅអាកាសយានដ្ឋានអន្តរជាតិពីប្រទេសជាច្រើនដែលកំពុងតែយាយីធ្ងន់ធ្ងរដោយបញ្ហាកូវីដ-១៩ ត្រូវបានហាមឃាត់ចាប់តាំងពីខែមិនាមក។ ការលើកបម្រាមនេះវិញកាលពីថ្ងៃ ២០ ខែឧសភា ត្រូវបានភ្ជាប់មកជាមួយនូវលក្ខខណ្ឌតម្រូវយ៉ាងតឹងរឹងសម្រាប់ជនបរទេសដែលមិនមែនជាទូត ចូលមកកម្ពុជា ដូចជាតម្រូវឲ្យមានលិខិតបញ្ជាក់សុខភាពថាមិនមានវិជ្ជមានវីរុសកូវីដ-១៩ ការធានារ៉ាប់រង សុខភាព ការធ្វើតេស្តពេលធ្វើដំណើរមកដល់ ការដាក់ឲ្យធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ និងការធ្វើតេស្តម្តងទៀតនៅថ្ងៃទី១៣។ កាលពីថ្ងៃទី ១១ វិច្ឆិកា ២០២០ ក្រសួងសុខាភិបាលបានដាក់អោយប្រើប្រាស់នូវគោលការណ៍ថ្មីស្តីពីការធ្វើដំណើរ និង ការអនុវត្តនូវវិធានការសុភាព និង ការធ្វើចត្តាឡីស័ក្ក ជាទូរទៅសំរាប់ជនបរទេស និង ជនជាតិខ្មែរ ដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងគ្មានជំរើសក្នុងការធ្វើចត្តាឡីស័ក្កនៅផ្ទះទៀតនោះឡើយ។ ចាប់ពីថ្ងៃទី ១៨ វិច្ឆិកា ២០២០ រាល់អ្នកដំណើរទាំងអស់ត្រូវធ្វើចត្តាឡីស័ក្កនៅកន្លែងដែលរាជរដ្ឋាភិបាលបានរៀបចំទុករួចជាស្រេច។ កាលពីថ្ងៃទី ១១ វិច្ឆិកា ២០២០ ក្រសួងមហាផ្ទៃបានផ្អាកជាបណ្តោះអាសន្ន នូវវេទិកាផ្សេងៗ ដូចជាការប្រជុំពិគ្រោះយោបល់នានា និងរាល់ការប្រជុំផ្សេងៗទៀតនូវរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ទាំងអស់ចំនួនពីរសប្តាហ៍ នៅទីក្រុងភ្នំពេញ និង ខេត្តកណ្តាល។
- កាលពីថ្ងៃទី ០៨ វិច្ឆិកា ក្រសួងសុខាភិបាល បានអំពាវនាវអោយមានការបិតទីកន្លែងកំសាន្ត និងទីកន្លែងហាត់ប្រាណរួមទាំងការបិទ មជ្ឈមណ្ឌលកំសាន្ត រោងភាពយន្ត មហោស្រព និងសារមន្ទីរនានាទូរទាំងប្រទេស។ កាលពី ១៨ វិច្ឆិកា រោងភាពយន្ត និង សារមន្ទីរទូរទាំងប្រទេសត្រូវបានអនុញាត្តិអោយបើកដំណើរឡើងវិញ។ កាលថ្ងៃទី ២៩ វិច្ឆិកា ក្រសួងអប់រំបានប្រកាសបិទសាលាឯកជនទាំងអស់ចំនួន ពីសប្តាហ៍



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

រាជរដ្ឋាភិបាលកម្ពុជា បានផ្អាកជាបណ្តោះអាសន្ននូវជើងហោះហើរពីប្រទេសម៉ាឡេស៊ី ហ្វីលីពីននិងប្រទេសឥណ្ឌូនេស៊ី តាំងពីខែសីហាមក។ ដោយសារថាកម្ពុជាមានហានិភ័យក្នុងការនាំចូលករណីវិជ្ជមានវីរុសកូវីដ-១៩ កម្រិតទាប ក្រុមហ៊ុនហោះហើរអន្តរជាតិកាន់តែច្រើនបានបើកដំណើរការជើងហោះហើរទៅមកភ្នំពេញឡើងវិញនៅក្នុងខែកញ្ញានេះ ដោយក្នុងនោះមានទាំងជើងហោះហើរពីទីក្រុងប៉េកាំង ពីសាំងហ្គាពួរ និងពីវៀតណាម (ដោយមានដាក់ការរឹតត្បិតខ្លះ)។ ក្រុមហ៊ុនអង្គរអ៊ែរកម្ពុជាបើកជើងហោះហើរក្នុងស្រុកឡើងវិញ និងជើងហោះហើរមួយសប្តាហ៍មួយជើងទៅកាន់ទីក្រុងក្វាងចូវ។ វិធានការមួយចំនួនក៏ត្រូវបានដាក់ចេញ មុននឹងការចូលមកដល់នៃពិធីចូលឆ្នាំខ្មែរផងដែរ ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ទៅសហគមន៍ណាមួយ។ ពិធីចូលឆ្នាំខ្មែរដែលជាធម្មតាត្រូវប្រារព្ធនៅខែមេសា ត្រូវបានលើកពេលមកប្រារព្ធនៅថ្ងៃទី១៧ ដល់ថ្ងៃ២១ ខែសីហាជំនួសវិញ ហើយពិធីបុណ្យអុំទូករយៈពេលបីថ្ងៃនៅខែតុលាត្រូវបានលុបចោល។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈ មិនមែនវេជ្ជសាស្ត្រ(NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | | | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬតម្រូវឲ្យ (Recommended or Required) | លើកសម្រាប់ វិស័យ/ផ្នែកខ្លះ (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | មិនមានទេ (None) | | | | |
| បិទសាលារៀន (School Closure) | ១៦ មិនា | ២៩ វិច្ឆិកា | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់លើកទេ (No) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នាច្រើន (Mass Gatherings) | ៣ មេសា | ០៨ វិច្ឆិកា | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ (Stay at Home) | រដ្ឋាភិបាលស្នើឲ្យនៅផ្ទះប្រសិនបើអាចធ្វើបាន (Government recommends stay home if possible) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា | មិនមានទេ (None) | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | ទេ (No) | លើកទាំងស្រុង (Yes) |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ (Restrictions on International Travel) | ២៧ មិនា | ១១ វិច្ឆិកា | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់ទេ (No) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី៩. ពេលវេលាអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ រួមបញ្ចូលជាមួយនឹងខ្សែកោងនៃការរាតត្បាតដោយជំងឺកូវីដ-១៩ (NPIs timeline combined with epidemic curve)**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។